# បាបនិងបុណ្យ

| | |
|---|---|
| បាបគឺអំពើដ៏អាក្រក់ | សម្លាប់លួចឆក់ខុសកាមេ |
| ជាមួយប្ដីប្រពន្ធកូនគេ | កុហកវៀចវេរបោកបញ្ឆោត ។ |
| ផឹកទឹកស្រវឹងគឺសុរា | មេរ័យកញ្ឆាអាភៀនសោត |
| ចិត្តលោភវង្វេង និងក្រេវក្រោធ | ទាំងអស់នោះសោតសុទ្ធតែបាប ។ |
| រីឯបុណ្យគឺអំពើល្អ | ចិត្តស្អាតបវរជាជរាប |
| វៀរចាកទាំងអស់អំពើបាប | ជោកទាបឆ្អេះឆ្អាបគ្រឿងសៅហ្មង។ |
| ធ្វើតែទាន សីល ភាវនា | គុណាគាប់ល្អជាពេកកន្លង |
| សាងសុខដល់ខ្លួននិងអ្នកផង | ឥតមានមោះហ្មងរាល់វេលា ៕ |

**ចាកបាបនិងបុណ្យ ឆ្នាំ ២០០៣**

**ឧទ្ទិស កុសល  ចំពោះឧបាសិកា ឌិត ឡេង**

# ផលបុណ្យ និងបាប

| | |
|---|---|
| អំពើបុណ្យ និង អំពើបាប | វាមានសភាពផ្ទុយពីគ្នា |
| បុណ្យតែងនាំឲ្យបានសុខជា | បាបនាំទុក្ខាជាប់ជានិច្ច ។ |
| បុណ្យដឹកនាំគេឲ្យរាប់អាន | បាបនាំរុញច្រានឲ្យគេភ្ញេច |
| បុណ្យតែងជួយឲ្យបានសម្រេច | បាបជួយកាត់ផ្ដាច់ខ្ទូចអសារ។ |
| បុណ្យនាំឲ្យសុខស្រុកមនុស្ស | ឯបាបទុយ៍សនាំទុក្ខា |
| បុណ្យនាំទៅកើតស្រុកទេព្ដា | បាបនាំអាត្មាចុះនរក ។ |
| បុណ្យតែងធ្វើចិត្តឲ្យភ្លឺថ្លា | បាបធ្វើចិន្ដាឲ្យលាមក |
| បុណ្យនាំវេខ្លួនចេញពីភក់ | បាបនាំដេកលក់ក្នុងភក់ជ្រាំ ។ |
| បុណ្យនាំសម្រេចព្រះនិព្វាន | បាបឃាត់ទប់ប្រាណនៅសោយកម្ម |
| ទុក្ខសោករោគភ័យអង្វែងឆ្នាំ | ដូចនេះត្រូវចាំ កុំធ្វើបាប ៕ |

# គេចមិនផុតពីបាបទេ

| | |
|---|---|
| *អ្នកធ្វើបាបកម្មកុំយល់ខុស* | *ថា  បាបកម្មនោះដូចទឹកឃ្មុំ* |
| *តែពិតបាបនោះពិសពុលធំ* | *ឲ្យទោសក្តៅធំគេចមិនផុត ។* |
| *ទោះបីទៅពួនក្នុងអាកាស* | *ក្នុងជលសាមហាសមុទ្រ* |
| *ឬក្នុងរូងភ្នំក៏មិនផុត* | *នឹងគេចវេះរត់ក៏មិនបាន ។* |
| *ទីណាដែលផុតពីផលបាប* | *ពោលរាលឆេះឆាបឥតស្រាកស្រាន្ត* |
| *ទីនោះព្រះពុទ្ធដ៏ទ្រង់ញាណ* | *សម្តែងថាគ្មានសោះទេឡើយ។* |
| *ដូចនេះត្រូវគិត គេចជាមុន* | *គឺខំធ្វើបុណ្យណាអ្នកអើយ* |
| *ឯត្រង់បាបកម្មកុំធ្វើឡើយ* | *ផុតពីបាបហើយសុខក្សេមក្សាន្ត ៕* |